ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កិច្ចប្រជុំខេត្តជាប់ព្រំដែន

ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០

កិច្ចប្រជុំពិភាក្សា ស្តីពី «ការពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងពលករឆ្លងដែនដោយខុសច្បាប់» ត្រូវបានប្រារព្ធធ្វើឡើង នាថ្ងៃពុធ ដប់ពីររោច ខែជេស្ឋ ឆ្នាំជូត ព.ស.ពីរពាន់ប្រាំរយហុកសិបបួន ត្រូវនឹងថ្ងៃទីដប់ប្រាំពីរ ខែមិថុនា ឆ្នាំពីរពាន់ម្ភៃ វេលាម៉ោង ប្រាំបី និងសាមសិបនាទីព្រឹក នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ ដឹកនាំដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការចូលរួមពី គណៈអភិបាលខេត្តចំនួនបួន រួមមាន៖ **ឯកឧត្តម អ៊ុំ រាត្រី** អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ឯកឧត្តម **នាក់ ណេរ៉ុន** និងលោកជំទាវ **ឃូ សតា** អភិបាលរងខេត្តសៀមរាប លោកជំទាវ **ស៊ុំ ចិន្តា** អភិបាលរងខេត្តបាត់ដំបង លោកជំទាវ **មុំ ពុទ្ធីតា** អភិបាលរងខេត្តឧត្តរមានជ័យ និងមានការអញ្ជើញចូលរួមពី **លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ **ឯកឧត្តម ឧត្តមសេនីយ៍ឯក សៀក សុជាតិ** នាយកទីចាត់ការការងារព្រំដែន នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ **ឯកឧត្តម សួស ប្រាថ្នា** អគ្គនាយករង និងជាប្រធាននាយកដ្ឋានរដ្ឋបាល នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ម៉ៃ ខ្វត្តម** អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន **ឯកឧត្តម លោកជំទាវ** អគ្គលេខាធិការរង លោកប្រធានលេខាធិការដ្ឋាន ប្រធានក្រុមការងារទាំង៦ នៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្នងការរង នៃស្នងការដ្ឋាននគរបាលខេត្តទាំង៤ ប្រធានវរៈនគរបាលការពារព្រំដែនគោក ប្រធាន អនុប្រធានច្រកទ្វារព្រំដែន ប្រធានប៉ុស្តិ៍អន្តោប្រវេសន៍ អស់លោក លោកស្រីប្រធាន និងតំណាងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត អភិបាល អភិបាលរងស្រុក នៃខេត្តបន្ទាយមានជ័យ និងមន្ត្រីពាក់ព័ន្ធមួយចំនួន និងមានការចូលរួមពីលោកស្រី ត្រិស្ទីន ផាក្វ នាយិកាប្រចាំប្រទេសអង្គការ IOM កម្ពុជា **សរុប ចំនួន៨៤ រូប ស្រី ១៩ រូប** ។

កិច្ចប្រជុំ មានគោលបំណង៖

១. ពង្រឹងការអនុវត្ត សេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃ លេខ១៣៩៦ សជណ ចុះថ្ងៃទី ២៣ ឧសភា ឆ្នាំ២០២០ ស្តីពីការទប់ស្កាត់ការឆ្លងដែនខុសច្បាប់តាមច្រករបៀង ។

២. រួមគ្នាគិត និងរកឲ្យឃើញនូវគន្លឹះដោះស្រាយ ដើម្បីទប់ស្កាត់ជាមុននូវបញ្ហាប្រឈមនឹងការអូសទាញពលករឲ្យទៅធ្វើការងារក្នុងប្រទេសថៃដោយខុសច្បាប់ ។

លទ្ធផលនៃកិច្ចប្រជុំៈ

អង្គប្រជុំ បានធ្វើការពិភាក្សាយ៉ាងផុលផុស និងផ្លាស់ប្តូរព័ត៌មាននិងបទពិសោធន៍ ស្តីពីស្ថានភាព វិធានការ ភាពប្រឈម និងដំណោះស្រាយ របស់ខេត្តទាំងបួន និង មតិយោបល់ជំនាញពាក់ព័ន្ធ។ អង្គប្រជុំ បានផ្តោតការយកចិត្តទុកដាក់ លើបញ្ហាមួយចំនួន ពាក់ព័ន្ធនឹងពលករវិលត្រឡប់ និងនីតិវិធីនៃការគ្រប់គ្រង លំហូរពលករឆ្លងកាត់ព្រំដែន ដែលព្យាយាមឆ្លងដែនទៅមកខុសច្បាប់ ក្នុងតំណាក់កាលនៃវិបត្តិខូវិដ ១៩ ។

ជាលទ្ធផលដែលបូកសរុបបាន មានដូចខាងក្រោមៈ

- ជាសំណូមពរ នៃអង្គប្រជុំ គឺស្នើសុំក្រសួងមហាផ្ទៃ ដាក់ចេញនូវគោលការណ៍ពាក់ព័ន្ធនឹងតួនាទីរដ្ឋបាលមូលដ្ឋាន ក្នុងការលើកកម្ពស់ការទទួលខុសត្រូវក្នុងស្ថានភាពនៃការឆ្លើយតបនឹងវិបត្តិខូវិដ ១៩ និងផលប៉ះពាល់
- គប្បីជម្រុញ លើកកម្ពស់វិធានការសំខាន់ៗ មានជាអាទិ៍ៈ
  - បន្តការការពារខ្លួន និងសហគមន៍ពីការឆ្លង និងចម្លងមេរោគខូវិដ ១៩
  - អប់រំផ្លាស់ប្តូរផ្នត់គំនិត «បំណាច់ធ្វើខ្ញុំគេ សុខចិត្តធ្វើខ្ញុំបរទេស» ឲ្យទទួលស្គាល់គុណតម្លៃ របស់ខ្លួន ក្នុងនាមជាពលរដ្ឋខ្មែរ ដែលកើត ធំធាត់រីកចម្រើន និងស្លាប់ដើម្បីខ្មែរ ជាជាងដើម្បីបរទេស
  - លើកទឹកចិត្ត និងផ្តល់ការគាំទ្រ ដល់ការខិតខំផលិត ការប្រើប្រាស់ផលិតផលក្នុងស្រុក និងប្រើប្រាស់សក្តានុពលដែលមាន ដើម្បីបង្កើតមុខរបរក្នុងស្រុក ជាជាងការផ្សងព្រេង ដោយគ្មានគោលដៅច្បាស់លាស់ នៅក្រៅប្រទេសដែលប្រកបដោយគ្រោះថ្នាក់ ខាតពេលវេលា និងមិនមានផលប្រយោជន៍
  - លើកកម្ពស់លក្ខខ័ណ្ឌការងារក្នុងស្រុក និងលុបបំបាត់ល្បិចបោកប្រាស់ កេងប្រវ័ញ្ចបៀវត្សរ៍កម្មករ
  - ស្រាវជ្រាវ កំណត់មុខសញ្ញា បង្ក្រាប និងលុបបំបាត់មេខ្យល់ ដែលព្យាយាមអូសទាញពលករឲ្យឆ្លងដែនទៅរកការងារ ឬទៅធ្វើការដោយខុសច្បាប់
- ខេត្តនីមួយៗ អាចយកបទពិសោធន៍ល្អៗ និងព័ត៌មានសំខាន់ៗទៅធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយ
- គួរមានវិធានការម៉ឺងម៉ាត់ ក្នុងការគ្រប់គ្រងពលករឆ្លងដែនព្រឹកល្ងាច និងតាមរដូវកាល ជាពិសេស ការគ្រប់គ្រងលំហូរពលករដែលមកពីខេត្តផ្សេង ដែលមិនស្ថិតក្នុងកិច្ចព្រមព្រៀងរវាងខេត្តជាប់ព្រំដែន
- គួរមានយន្តការសម្របសម្រួលការវិលត្រឡប់ទៅធ្វើការវិញ របស់ពលករ ដើម្បីបញ្ចៀសភាពអាណាធិបតេយ្យ និងគ្មានច្បាប់អនុញ្ញាតត្រឹមត្រូវ ដែលនាំឲ្យមានការកេងប្រវ័ញ្ច និងការជួញដូរមនុស្សជាថ្មី
- ពង្រឹងការបិទច្រកមិនផ្លូវការ ក្នុងនោះ នៅខេត្តបាត់ដំបង មាន១៣ បន្ទាយមានជ័យ ៥២ ឧត្តរមានជ័យ ១៤ និងនៅព្រះវិហារ ពោធិសាត់ កោះកុង ។ល។

- ខេត្តដែលជាប់ពាក់ព័ន្ធនឹងការវិលត្រឡប់របស់ពលករពីប្រទេសគោលដៅ គប្បីមានការទទួលខុសត្រូវរៀងៗខ្លួន រួមជាមួយខេត្តជាប់ព្រំដែន ក្នុងនោះ មានករណីពលករមកដល់ថ្មី ពាក់ព័ន្ធនឹងខេត្តកំពង់ចាម កំពង់ធំ ត្បូងឃ្មុំ ជាដើម ។
- ខេត្តនីមួយៗគួរបង្កើតលេខទូរស័ព្ទ Hotline ដើម្បីទទួលព័ត៌មានពីមជ្ឈដ្ឋានខាងក្រៅ ។

ជាក្តីបារម្ភ៖

បណ្តាខេត្ត និងក្រសួងស្ថាប័ន មិនទាន់យល់ច្បាស់អំពី នយោបាយទេសន្តរប្រវេសន៍ និងគោលការណ៍នៃការគ្រប់គ្រងកម្លាំងពលកម្មសម្រាប់ការងារក្នុងស្រុក ថាតើគួរផ្តល់ឱកាសឲ្យមានការហូរចេញកម្លាំងពលកម្មប្រភេទណា? ត្រូវរក្សាទុកកម្លាំងរបៀបណា? ធ្វើដូចម្តេច? ។

មិនទាន់មានវិធានការជាក់លាក់ ក្នុងការសម្របសម្រួលការវិលត្រឡប់ទៅធ្វើការជាថ្មីរបស់ពលករដែលនឹងជួបប្រទះបញ្ហាច្របូកច្របល់ នៅពេលដែលប្រទេសថៃ មានវិធានការបើកច្រកព្រំដែនឡើងវិញ ។

ទោះបីជាយ៉ាងណាក្តី បណ្តាខេត្តជាប់ព្រំដែន គប្បីបន្តអនុវត្តតាមវិធានការរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានស្រាប់ ពាក់ព័ន្ធនឹងការគ្រប់គ្រងព្រំដែន ការបិទច្រករបៀងមិនផ្លូវការ និងការទប់ស្កាត់ការឆ្លងដែនខុសច្បាប់ ការស្រាវជ្រាវ និងបង្ក្រាបមេខ្យល់ រហូតដល់មានគោលការណ៍ណែនាំថ្មី ដើម្បីជៀសវាងបាតុភាពផ្សេងៗ ដែលនាំមកនូវរលកថ្មីនៃអំពើជួញដូរមនុស្ស ។

កិច្ចប្រជុំពិភាក្សាបានបញ្ចប់ នាវេលាម៉ោង ដប់ពីរ និងសែសិបនាទី ថ្ងៃខែឆ្នាំដដែល ប្រកបដោយលទ្ធផលជាផ្លែផ្កា ។

ថ្ងៃ ៣ ក្រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០

**អនុប្រធានអចិន្ត្រៃយ៍**

**ជូ_ប៊ុនអេង**